# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបក្រុមកីឡាករវាយកូនបាល់កម្ពុជា ដែលទើបមកពីប្រកួតកីឡា SEA Game នៅប្រទេស សឹង្ហបុរី



នៅរសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានហព័ន្ធកីឡាវាយកូនបាល់កម្ពុជា បានអនុញ្ញាតឱ្យក្រុមកីឡាករវាយកូនបាល់កម្ពុជាមួយក្រុម ដឹកនាំដោយ ឯកឧត្តម ទេព វិទ្ធិរិទ្ធ អគ្គលេខាធិការកីឡាវាយកូនបាល់កម្ពុជា ដើម្បីសំដែងការគួរសម និង រាយការណ៍ពីលទ្ធផលនៃការប្រកួតកីឡាវាយកូនបាល់កម្ពុជា ក្នុងព្រឹត្តិការណ៍ប្រកួតកីឡា **SEA Game** លើកទី២៨ នៅ ប្រទេសសឹង្ហបុរី ។



ឯកឧត្តម ទេព វិទ្ធិរិទ្ធ អគ្គលេខាធិការកីឡាវាយកូនបាល់កម្ពុជា បានមានប្រសាសន៍ជម្រាបថាៈការប្រកួតកីឡា SEA Game លើកទី២៨ នៅប្រទេស សឹង្ហបុរី នេះ កម្ពុជាបានបញ្ជូនកីឡាករវាយកូនបាល់ចំនួន ០៦ រូប ប្រុស ០៤រូប និងស្រី ចំនួន០២ រូប ដើម្បីចូលរួមប្រកួត ក្នុងលក្ខណៈជាក្រុម និង ទោល ។ ជាលទ្ធផល កម្ពុជាទទួលបានមេដាយសំរិទ្ធ ក្នុងលក្ខណៈប្រកួត ទោល ដោយកីឡាករ **ប៊ុន គីនី** ។

ឯកឧត្តម ទេព វិទ្ធិរិទ្ធ បាននំលឹកថាៈកម្ពុជា បានបញ្ជូនកីឡាករវាយកូនបាល់ ទៅប្រកួត កីឡា SEA Game ចាប់តាំងពីឆ្នាំ២០០៧ មក ។ រាល់ការប្រកួត គឺកម្ពុជា ទទួលបានមេដាយ សំរិទ្ធជានិច្ច លើកលែង តែនៅឆ្នាំ ២០១៣ ដែលការប្រកួត កីឡា SEA Game នៅប្រទេសភូមា ត្រូវប្រទេសម្ចាស់ផ្ទះដកវិញ្ញាសារកីឡានេះចេញ ។ ជាពិសេស អ្វីដែលកម្ពុជាមានមោទនៈភាពនោះ គឺនៅឆ្នាំ ២០១១ ក្នុងព្រឹត្តិការណ៍ប្រកួតកីឡា SEA Game នៅប្រទេសឥណ្ឌូនេស៊ី កម្ពុជាទទួលបានមេដាយសំរិទ្ធ ក្នុងលក្ខណៈប្រកួតជាក្រុម ព្រោះការប្រកួតជាក្រុម កម្ពុជាពុំធ្លាប់ទទួលបាន ជ័យលាភីឡើយ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កីឡាករវាយកូនបាល់កម្ពុជា ទាំងប្រភេទនារី និងបុរស ដែលឯកឧត្តមបានចាត់ទុកថា ជាការកសាងប្រវត្តិសាស្ត្រថ្មីសម្រាប់កម្ពុជា ព្រោះកីឡាប្រភេទនេះ ធ្លាប់មានឈ្មោះល្បីតាំងពីទស្សវត្សឆ្នាំ៦០មកម្លេះ ហើយកីឡាករ ដ៏ល្បីរបស់កម្ពុជា ឈ្មោះ **ទេព ឃុនណា** ។ ហើយអ្វីដែលកម្ពុជា មិនធ្លាប់ទទួលបាននោះ គឺកម្ពុជា បានចូលរួមប្រកួត ក្នុងព្រឹត្តការណ៍Divis Cup នៅប្រទេស អារ៉ាប់ អេមីរ៉ាត់ និងនៅប្រទេសអ៊ីរ៉ង់ គឺកម្ពុជា ចាប់ផ្តើមចូលរួមប្រកួតភ្លាម បានរំកិលចំណាត់ថ្នាក់ពីក្រុមប្រទេសទី៤ មកចំណាត់ថ្នាក់ក្រុមប្រទេសទី៣ ដែលធ្វើឱ្យកម្ពុជាទទួលការចាប់អារម្មណ៍ពីមជ្ឈដ្ឋានកីឡាអន្តរជាតិ ។

ឯកឧត្តម បានកោតសរសើរ ដល់ឯកឧត្តមអគ្គលេខាធិការ ទេព វិទ្ធិរិទ្ធ និងគ្រូបង្វឹង ដែលបានដឹកនាំសហព័ន្ធ និងបង្ហាត់បង្រៀនដល់កីឡាករវាយកូនបាល់កម្ពុជា ឱ្យកាន់តែមានសមត្ថភាពក្នុងអាជីពរបស់ខ្លួន ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានដាស់តឿនដល់កីឡាករទាំងអស់ខិតខំ បង្កើនសមត្ថភាព ដកស្រង់បទពិសោធន៍ ជាពិសេស ស្តាប់ការណែនាំរបស់គ្រូបង្វឹង និងថែទាំសុខភាពឱ្យបានល្អ។ ទន្ទឹមគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានផ្តល់សារៈសំខាន់ ចំពោះការជ្រើសរើសកីឡាករថ្មីៗក្មេងៗ ជាពិសេស ពីមជ្ឈមណ្ឌលកុមារកំព្រា ដែលពួកគេមានការអប់រំក្នុងបន្ទុករបស់អង្គការ រឺមជ្ឈមណ្ឌលងាយស្រួលក្នុងការបណ្តុះបណ្តាលឱ្យក្លាយជាកីឡាករអាជីពបាន ។

ស្ថិតក្នុងឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានឧបត្ថម្ភថវិកាមួយចំនួន ដល់សហព័ន្ធ និងកីឡាករ ទទួលបានជ័យលាភីផងដែរ ។

